ព្រះរាជាណាចក្រកម្ពុជា

ជាតិ សាសនា ព្រះមហាក្សត្រ

សាលាឧទ្ធរណ៍

សំណុំរឿងព្រហ្មទណ្ឌ

លេខ:៤៦១/០៨-៩-២០០៨

សាលដីកា

លេខ:៤៥(ច)/២៨-៨-២០០៩

## គាននាមប្រជារាស្ត្រខ្មែរ

## សាលាឧទ្ធរណ៍ភ្នំពេញ

បង្កើតឡើងតាមច្បាប់ស្តីពីការចាត់តាំង និង សកម្មភាពរបស់សាលាជម្រះក្តី ដែលប្រកាសឱ្យប្រើតាមក្រឹត្យលេខ:០៦ក្រ ចុះថ្ងៃទី០៨-០២-១៩៩៣ បានបើកសវនាការជាសាធារណៈនៅសាលាឧទ្ធរណ៍ នាថ្ងៃទី២៨-៨-២០០៩ ដែលមានសមាសភាពដូចតទៅ :

**សមាសភាពក្រុមប្រឹក្សា**

លោក [redacted] ជាប្រធាន

លោក [redacted] ជាចៅក្រមប្រឹក្សា

លោក [redacted] ជាចៅក្រមប្រឹក្សា

**តំណាងមហាអយ្យការ**

លោក [redacted]

**ក្រឡាបញ្ជីសវនាការ**

លោក [redacted]

ដើម្បីជំនុំជម្រះលើបណ្តឹងឧទ្ធរណ៍នៃរឿងព្រហ្មទណ្ឌលេខ:៤៦១ ចុះថ្ងៃទី០៨-៩-២០០៨ រវាង :

-ជនជាប់ចោទឈ្មោះ [redacted] **ឈុនលី** ភេទប្រុស អាយុ២១ឆ្នាំ ជាតិខ្មែរ មុខរបរធ្វើស្រែ កើតនៅភូមិស្វាយលើ ឃុំព្រែកតាមាក់ ស្រុកខ្សាច់កណ្តាល ខេត្តកណ្តាល ទីលំនៅសព្វថ្ងៃភូ[redacted] កណ្តាល ខេត្តកណ្តាល ឪពុកឈ្មោះ [redacted](រ) ម្តាយឈ្មោះ [redacted](រ) នៅលីវ ទោសពីមុនគ្មាន ។ ឃុំខ្លួនថ្ងៃទី២៦-១១-២០០៧ ។

មេធាវីការពារឈ្មោះ [redacted] ទ៉ាច

ត្រូវជាប់ចោទពីបទ: ប្លន់(ឆក់ខ្សែស័ក្តិដៃ) ប្រព្រឹត្តនៅស្ទួនច្បារមាត់ទន្លេ សង្កាត់ផ្សារកណ្តាល១ ខណ្ឌដូនពេញ ក្រុងភ្នំពេញ កាលពីថ្ងៃទី២៣-១១-២០០៧ បទល្មើសព្រហ្មទណ្ឌដែលមានចែង និង ផ្តន្ទាទោសតាមបញ្ញត្តិមាត្រា៦ នៃច្បាប់ស្តីពីស្ថានទម្ងន់ទោសនៃបទឧក្រិដ្ឋ ។

-ដើមបណ្តឹងរដ្ឋប្បវេណីឈ្មោះ [redacted] ឆូ ភេទស្រី ជាតិខ្មែរ ទីលំនៅសព្វថ្ងៃស្នាក់នៅសណ្ឋាគារវណ្ណចិន ផ្លូវលេខ១៣០ សង្កាត់ផ្សារកណ្តាល១ ខណ្ឌដូនពេញ ក្រុងភ្នំពេញ ។

តាមពាក្យបណ្តឹងឧទ្ធរណ៍ ចុះថ្ងៃទី២០-៦-២០០៨ របស់ឈ្មោះ [redacted] ប្តឹងឧទ្ធរណ៍នឹងសាលក្រម លេខ:៥៨ ក្រ១ ចុះថ្ងៃទី០៥-៦-២០០៨ របស់តុលាការក្រុងភ្នំពេញ ត្រង់ចំណុចនៃសេចក្តីសម្រេចទាំងមូល ។

**<u>ឯរឿងហេតុមានដូចតទៅ</u>**

តាមពាក្យបណ្តឹងរបស់ឈ្មោះ [redacted] ឆ្វ កាលពីថ្ងៃទី២៣-១១-២០០៧ វេលាម៉ោង១៦:៣០នាទី ខ្លួននឹងមិត្តភ័ក្រ្ត៦នាក់ បាននាំគ្នាដើរពីកន្លែងធ្វើការសណ្ឋាគារឥណ្ឌូចិន ទៅលេងមាត់ទន្លេ មើលគេអុំទូក រហូតដល់ម៉ោង១៨:២០នាទី ពេលដែលខ្លួនកំពុងឈរមើលគេបាញ់កាំជ្រួច ក៏មានជនល្មើសម្នាក់ភេទប្រុស បានធ្វើសកម្មភាពឆក់ទូរស័ព្ទដៃពីខ្លួនដែលបំរុងយកមកទំនាក់ទំនងមិត្តភ័ក្រ្ត ភ្លាមនោះខ្លួនបានដឹងខ្លួនទាន់ ហើយស្រែកឡូឡាក៏សមត្ថកិច្ចដែលប្រចាំការនៅក្បែរនោះដេញចាប់បានជនល្មើស និង ដកហូតទូរស័ព្ទដៃម៉ាកម៉ូតូរ៉ូឡាខ្លួនមកវិញ ។

-តាមចម្លើយរបស់ជនជាប់ចោទឈ្មោះ [redacted] **ឈុនលី** ឆ្លើយថា: កាលពីថ្ងៃទី២៣-១១-២០០៧ វេលាម៉ោង១៨:៣០នាទីយប់ ខ្លួនបានដើរលេងមើលក្នុងពិធីអុំទូក ក៏ឃើញក្មេងស្រីម្នាក់និយាយទូរស័ព្ទ ខ្លួនក៏បានលូកដៃយកទូរស័ព្ទដៃរត់គេចខ្លួនតែម្តង តែដោយម្ចាស់គេស្រែកឡូឡា អ្នកនៅជិតខ្លួនក៏ចាប់ខ្លួនបានតែម្តង ។ ចំពោះទូរស័ព្ទដៃរបស់ជនរងគ្រោះ ម្ចាស់គេបានដកយកវិញ ពេលប្រជាជនចាប់ខ្លួនបានភ្លាម១នោះ ។ ចំពោះអំពើដែលខ្លួនធ្វើនេះ ខ្លួនបានដឹងថា ជាអំពើខុសឆ្គងនឹងច្បាប់ ដូចនេះខ្លួនសុំសំណូមពរសុំឱ្យតុលាការ មេត្តាជួយបន្ធូរបន្ថយទោសឱ្យខ្លួនដោយអនុគ្រោះ ។

-តាមចម្លើយដើមបណ្តឹងរដ្ឋប្បវេណីឈ្មោះ [redacted] ឆ្វ ឆ្លើយថា: កាលពីថ្ងៃទី២៣-១១-២០០៧ វេលាម៉ោង១៦:៣០នាទី ខ្លួននឹងមិត្តភ័ក្រ្ត៦នាក់ បាននាំគ្នាដើរលេង ចេញពីកន្លែងធ្វើការសណ្ឋាគារឥណ្ឌូចិន២ មកមាត់ទន្លេមើលគេអុំទូក រហូតដល់ម៉ោង១៨:២០នាទី ពេលដែលខ្លួនកំពុងឈរមើលគេបាញ់កាំជ្រួច ក៏មានគេទំនាក់ទំនងចូលមកទូរស័ព្ទដៃរបស់ខ្លួន រួចខ្លួនបានលើកយកទូរស័ព្ទមកបំរុងទទួល ក៏មានជនល្មើសម្នាក់បានឆក់យកទូរស័ព្ទដៃពីខ្លួន រួចរត់គេចខ្លួន ខ្លួនក៏ស្រែកឡូឡា សមត្ថកិច្ចដែលប្រចាំការនៅក្បែរនោះ បានចាប់ជនល្មើសបាន និង ដកហូតយកទូរស័ព្ទដៃរបស់ខ្លួនមកខ្លួនវិញ ។

បានឃើញសាលក្រមលេខ:៩៨ ក្រ.១ ចុះថ្ងៃទី០៥-៦-២០០៨ របស់តុលាការក្រុងភ្នំពេញ ដែលមានខ្លឹមសារនៃសេចក្តីសំរេចដូចតទៅ :

១-កែប្រែបទចោទប្រកាន់លើឈ្មោះ [redacted] **ឈុនលី** ភេទប្រុស អាយុ១៩ឆ្នាំ ពីបទ:ប្លន់ឆក់ទូរស័ព្ទ ប្រព្រឹត្តនៅសួនច្បារមាត់ទន្លេ សង្កាត់ផ្សារកណ្តាល១ ខណ្ឌដូនពេញ ក្រុងភ្នំពេញ កាលពីថ្ងៃទី២៣-១១-២០០៧ បទល្មើសដែលមានចែង និង ឱ្យផ្តន្ទាទោសតាមមាត្រា៦ នៃច្បាប់ស្តីពីស្ថានទម្ងន់ទោសនៃបទឧក្រិដ្ឋ មកបទ:ចោរកម្មលួចទូរស័ព្ទ វិញ ប្រព្រឹត្តនៅសួនច្បារមាត់ទន្លេ សង្កាត់ផ្សារកណ្តាល១ ខណ្ឌដូនពេញ ក្រុងភ្នំពេញ កាលពីថ្ងៃទី២៣-១១-២០០៧ បទល្មើសដែលមានចែង និង ឱ្យផ្តន្ទាទោសតាមមាត្រា៤៣ នៃច្បាប់ព្រហ្មទណ្ឌអន្តរកាល ។

២-ផ្តន្ទាទោសឈ្មោះ [redacted] **ឈុនលី** ដាក់ពន្ធនាគារកំណត់០១ឆ្នាំ( មួយឆ្នាំ) គត់ គិតពីថ្ងៃឃុំខ្លួនថ្ងៃទី២៦-១១-២០០៧ ពីបទ:អំពើចោរកម្មលួចទូរស័ព្ទ ប្រព្រឹត្តនៅសួនច្បារមាត់ទន្លេ សង្កាត់ផ្សារកណ្តាល១ ខណ្ឌដូនពេញ ក្រុងភ្នំពេញ កាលពីថ្ងៃទី២៣-១១-២០០៧ បទល្មើសដែលមានចែង និង ឱ្យផ្តន្ទាទោសតាមមាត្រា៤៣ នៃច្បាប់ព្រហ្មទណ្ឌអន្តរកាល ។ល។

៣-សាលក្រមនេះជំនុំជម្រះកាលពីថ្ងៃទី២០-៥-២០០៨ ប្រកាសនៅថ្ងៃទី០៥-៦-២០០៨ ចំពោះមុខជនជាប់ចោទ កំបាំងមុខដើមបណ្តឹងរដ្ឋប្បវេណី ទុកសិទ្ធិប្តឹងទាស់ និង បើកផ្លូវឱ្យប្តឹងឧទ្ធរណ៍ ក្នុងកំណត់ច្បាប់ ។

-បានឃើញរបាយការណ៍ ចុះថ្ងៃទី១០-១០-២០០៨ របស់ចៅក្រមរបាយការណ៍សាលាឧទ្ធរណ៍ ។

-បានឃើញសេចក្តីសន្និដ្ឋាន ចុះថ្ងៃទី១៧-១១-២០០៨ របស់ព្រះរាជអាជ្ញាសាលាឧទ្ធរណ៍ ។

**នាពេលសវនាការ**

-ជនជាប់ចោទឈ្មោះ [redacted] **ឈុនលី** ឆ្លើយថា: ខ្លួនទទួលស្គាល់ថា បានប្រព្រឹត្តមែន គឺពេលគេដកហូតទូរស័ព្ទពីហោប៉ៅ ខ្លួនក៏ឆក់យកតែម្តង ពេលឆក់មានតែខ្លួនម្នាក់ឯងទេ ។ ខ្លួនសុំឱ្យសាលាឧទ្ធរណ៍តម្កល់សាលក្រមដដែល ។

-តំណាងមហាអយ្យការសន្និដ្ឋានថា: ពេលជនរងគ្រោះដកទូរស័ព្ទពីហោប៉ៅ ជនល្មើសបានប្រើអំពើហិង្សាដោយឆក់ទូរស័ព្ទរបស់ជនរងគ្រោះ ហើយជនរងគ្រោះបានស្រែកឱ្យគេជួយ ។ ដូច្នេះការកែប្រែបទចោទប្រកាន់របស់សាលាដំបូងក្រុងភ្នំពេញ មិនត្រឹមត្រូវទេ សូមឱ្យក្រុមប្រឹក្សាកែប្រែពីបទៈចោរកម្ម ទៅជាបទៈប្លន់ វិញ យោងតាមមាត្រា៦ នៃច្បាប់ស្តីពីស្ថានទម្ងន់ទោសនៃបទឧក្រិដ្ឋ ។

-មេធាវី [redacted] **ម៉ាច** ការពារជនជាប់ចោទសន្និដ្ឋានថា: ការដែលតំណាងមហាអយ្យការ ចោទប្រកាន់កូនក្តីខ្លួនពីបទៈប្លន់ មិនត្រឹមត្រូវទេ ព្រោះពេលដែលជនរងគ្រោះដកទូរស័ព្ទចេញពីហោប៉ៅ ក៏ឆក់យកតែម្តង មិនបានប្រើអំពើហិង្សា និង មានគ្នាច្រើនទេ ហេតុនេះសុំឱ្យតម្កល់សាលក្រមសាលាដំបូងក្រុងភ្នំពេញ ដដែល ។

-ក្រោយពីបានស្តាប់ចម្លើយរបស់ ជនជាប់ចោទ

-ក្រោយពីបានស្តាប់សេចក្តីសន្និដ្ឋាន តំណាងមហាអយ្យការ

-ក្រោយពីបានស្តាប់សេចក្តីសន្និដ្ឋាន មេធាវីការពារជនជាប់ចោទ

-ក្រោយពីបានពិនិត្យគ្រប់ឯកសារ

-ក្រោយពីបានពិចារណាត្រឹមត្រូវហើយ

**សាលាឧទ្ធរណ៍**

១-យល់ឃើញថា: ពាក្យបណ្តឹងឧទ្ធរណ៍ចុះថ្ងៃទី២០-៦-២០០៨ របស់ព្រះរាជអាជ្ញារងអមសាលាដំបូងក្រុងភ្នំពេញ ធ្វើឡើងតាមកំណត់ច្បាប់ សាលាឧទ្ធរណ៍ទទួលជំនុំជម្រះបាន យោងតាមបញ្ញត្តិមាត្រា៣៨១ នៃក្រមនីតិវិធីព្រហ្មទណ្ឌ ។

២-យល់ឃើញថា: តាមចម្លើយរបស់ជនរងគ្រោះ និង ចម្លើយរបស់ជនជាប់ចោទ បានបញ្ជាក់ឱ្យឃើញថា នៅថ្ងៃទី២៣-១១-២០០៧ វេលាម៉ោង១៨និង២០នាទីយប់ នៅសួនច្បារមាត់ទន្លេ សង្កាត់ផ្សារកណ្តាលទី១ ខណ្ឌដូនពេញ ក្រុងភ្នំពេញ នៅពេលដែលជនរងគ្រោះឈ្មោះ [redacted] ឌូ កំពុងនិយាយទូរស័ព្ទនោះ ស្រាប់តែជនជាប់ចោទឈ្មោះ [redacted] **ឈុនលី** បានលួចឆក់យកទូរស័ព្ទរបស់ជនរងគ្រោះ រួចរត់គេចខ្លួន តែត្រូវជនរងគ្រោះស្រែក ហើយប្រជាជនក៏ចាប់បានជនជាប់ចោទតែម្តង ។/



Scanned with CamScanner

៣-យល់ឃើញថាៈ ជនជាប់ចោទបានប្រព្រឹត្តអំពើល្មើសតែម្នាក់ឯង ហើយជនជាប់ចោទពុំបានប្រើហិង្សាទៅលើជនរងគ្រោះឡើយ ដែលអំពើនេះគឺជាអំពើចោរកម្ម ។

៤-យល់ឃើញថាៈ មានភស្តុតាង និង ពិរុទ្ធភាពគ្រប់គ្រាន់លើឈ្មោះ [redacted] **ឈុនលី** ពីបទៈចោរកម្ម ប្រព្រឹត្តនៅស្តូនច្បារមាត់ទន្លេ សង្កាត់ផ្សារកណ្តាលទី១ ខណ្ឌដូនពេញ ក្រុងភ្នំពេញ កាលពីថ្ងៃទី២៣-១១-២០០៧ បទល្មើសព្រហ្មទណ្ឌដែលមានចែងឱ្យផ្តន្ទាទោសតាមមាត្រា៤៣ នៃច្បាប់ព្រហ្មទណ្ឌអន្តរកាល ។

៥-យល់ឃើញថាៈ រឿងក្តីនេះសាលាដំបូងក្រុងភ្នំពេញ បានធ្វើការអង្កេត និង លើកយកភស្តុតាងមកសំអាងជូនសព្វគ្រប់ហើយ សាលាឧទ្ធរណ៍ឯកភាពលើសំអាងហេតុនេះ ដូចនេះសាលាឧទ្ធរណ៍ ពុំចាំបាច់លើកយកសំអាងហេតុដដែលនេះ មកបញ្ជាក់ជាថ្មីទៀតទេ ។

៦-យល់ឃើញថាៈ សាលក្រមព្រហ្មទណ្ឌលេខៈ៥៨ ក្រ១ ចុះថ្ងៃទី០៥-៦-២០០៨ របស់សាលាដំបូងក្រុងភ្នំពេញ ដែលសម្រេចសេចក្តីមកនេះ មានលក្ខណៈត្រឹមត្រូវហើយ គប្បីតម្កល់ទុកជាបានការដដែល ដោយគ្រាន់តែកែប្រែរយៈពេលនៃការផ្តន្ទាទោសលើជនជាប់ចោទ ឱ្យបានសមរម្យ ។

## <u>ហេតុដូច្នេះវិនិច្ឆ័យសេចក្តី</u>

១-ទទួលពាក្យបណ្តឹងឧទ្ធរណ៍ ចុះថ្ងៃទី២០-៦-២០០៨ របស់លោកព្រះរាជអាជ្ញារងអមសាលាដំបូងក្រុងភ្នំពេញ ទុកជាត្រឹមត្រូវតាមទម្រង់ច្បាប់ ។

២-តម្កល់សាលក្រមព្រហ្មទណ្ឌលេខៈ៥៨ ក្រ១ ចុះថ្ងៃទី០៥-៦-២០០៨ របស់សាលាដំបូងក្រុងភ្នំពេញ ទុកជាបានការដដែល ដោយគ្រាន់តែកែប្រែរយៈពេលនៃការផ្តន្ទាទោស លើជនជាប់ចោទក្នុងចំណុចទី២ នៃសេចក្តីសម្រេចពីរយៈពេល០១(មួយ)ឆ្នាំ មកជារយៈពេល០១(មួយ)ឆ្នាំ ១០(ដប់)ខែ វិញ ។ ចំណុចក្រៅពីនេះ រក្សាទុកជាបានការដដែល ។

៣-សាលដីកានេះជំនុំជម្រះ និង ប្រកាសជាសាធារណៈ ចំពោះមុខជនជាប់ចោទ និង មេធាវីការពារជនជាប់ចោទ. កំបាំងមុខដើមបណ្តឹងរដ្ឋប្បវេណី បើកផ្លូវប្តឹងតវ៉ា តាមកំណត់ច្បាប់ ។ល៉/

**សេចក្តីនេះ ព្រះមហាក្សត្រនៃព្រះរាជាណាចក្រកម្ពុជា ទ្រង់ត្រាស់បង្គាប់មកមន្ត្រីទទួលបន្ទុកអនុវត្តសាលដីកា ស្ថាប័នមានសមត្ថកិច្ចគ្រប់ថ្នាក់ គ្រប់តំណែង និង គងកំលាំងប្រដាប់អាវុធ ជួយសហការអនុវត្តសាលដីកានេះឱ្យបានសម្រេច ប្រសិនបើមានសំណូមពរត្រឹមត្រូវតាមច្បាប់ ។ល៉/**

| ក្រឡាបញ្ជី | ចៅក្រមប្រឹក្សា | ប្រធានក្រុមប្រឹក្សាជំនុំជម្រះ |
| --- | --- | --- |
| ហត្ថលេខា [redacted] | ហត្ថលេខា [redacted] [redacted] | ហត្ថលេខា [redacted] |

| | |
| --- | --- |
| បានឃើញ | បានចម្លងត្រឹមត្រូវតាមច្បាប់ដើម |
| ប្រធានសាលាឧទ្ធរណ៍ | ភ្នំពេញ ថ្ងៃទី 30 ខែ 5 ឆ្នាំ ២០១៤ |
| | ក្រឡាបញ្ជី |
| [redacted] | [redacted] |



Scanned with CamScanner